**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# សន្និសីទសារព័ត៌មានៈ «សមិទ្ធផល៥ឆ្នាំ នៃកំណែទម្រង់រដ្ឋបាលសាធារណៈ និងវិស័យមុខងារសាធារណៈ»

ក្រសួងមុខងារសាធារណៈសូមជម្រាបជូនមន្ត្រីរាជការសាធារណៈ និងសាធារណជនទាំងអស់ មេត្តាជ្រាបថា នៅព្រឹកថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល បានរៀបចំសន្និសីទសារព័ត៌មានស្តីពី «**សមិទ្ធផល៥ឆ្នាំ នៃកំណែទម្រង់រដ្ឋបាលសាធារណៈ និងវិស័យមុខងារសាធារណៈ**» នៅទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានវត្តមានរបស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងមន្ត្រីជាន់ខ្ពស់មួយចំនួនរបស់ក្រសួងមុខងារសាធារណៈ ចូលរួមជាវាគ្មិន។

ក្នុងសន្និសីទនេះ **ឯកឧត្តមរដ្ឋមន្ត្រី ហ៊ុំ សុខា** បានថ្លែងគូសបញ្ជាក់ដោយសង្ខេបពីសមិទ្ធផលសំខាន់ៗ រយៈពេល៥ឆ្នាំ របស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំកំណែទម្រង់រដ្ឋបាលសាធារណៈ និងវិស័យមុខងារសាធារណៈ។

ក្រោយពីការថ្លែងខ្លឹមសារបាឋកថារយៈពេល២ម៉ោង និងការបកស្រាយសំណួរមួយចំនួនរបស់អ្នកសារព័ត៌មានរួចមក សន្និសីទសារព័ត៌មាន ត្រូវបានបញ្ចប់ប្រកបដោយលទ្ធផលល្អប្រសើរ។

អាស្រ័យហេតុនេះ សូមមន្ត្រីរាជការសាធារណៈ និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ចំពោះខ្លឹមសារលម្អិតទាំងស្រុងនៃសន្និសីទសារព័ត៌មានខាងលើនេះ អាចចូលតាមដាន និងទស្សនាវីដេអូបានតាមរយៈតំណភ្ជាប់ខាងក្រោម៖

- បណ្តាញសង្គមរបស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល៖ https://fb.watch/ggsC6f34KZ/ ឬ
- គេហទំព័ររបស់ក្រសួងមុខងារសាធារណៈ៖ https://www.mcs.gov.kh/?p=43160 ឬ
- បណ្តាញសង្គមផ្លូវការរបស់ក្រសួងមុខងារសាធារណៈ (យូធូប)៖ https://youtu.be/fGaxAJg1Qrw ៕

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២

ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh